បណ្ណព័ត៌មាន 7

# រក្សាវាឲ្យបានស្អាតសំរាប់ទីវាលដាំបន្លែ

## ចលនាទៅមកនៃយានយន្ត និងតំបន់បន្ថយគ្រោះថ្នាក់

Virginia Brunton & Jeremy Badgery-Parker, Ourimbah

### ចលនាទៅមកនៃយានយន្ត និងគ្រឿងម៉ាស៊ីន

យានយន្ត និងគ្រឿងម៉ាស៊ីនដែលទៅមកលើចំការ គឺជាហានិភ័យខ្ពស់ ដោយការនាំចូលនូវសត្វចង្រៃ មានរួមទាំងសត្វល្អិត សត្វចៃ សត្វព្រូន គ្រាប់រុក្ខជាតិតូចៗ និងគ្រាប់ស្មៅឥតប្រយោជន៍ និងជម្ងឺផងដែរ។ យានយន្តដែលប្រើសំរាប់ប្រគល់ និងប្រមូលទំនិញ ជាញឹកញាប់ ធ្វើដំណើរពីចំការមួយ ទៅចំការមួយទៀត បង្កើតឲ្យមានឱកាសយ៉ាងច្រើនសំរាប់ឲ្យសត្វចង្រៃតោងយានយន្តនៅតាមផ្លូវ មកដល់ចំការរបស់លោកអ្នក ហើយចូលទៅក្នុងដំណាំរបស់លោកអ្នក។ អ្នកធ្វើការក្រោមកិច្ចសន្យាដែលត្រួតពិនិត្យសាបព្រោះ បាចសាចទឹក និងច្រូតកាត់ប្រមូលផល ក៏ធ្វើដំណើរទៅមកពីចំការមួយទៅចំការមួយទៀតដែរ។

យានយន្តទាំងអស់ មានរួមទាំងរថយន្តដឹកទំនិញ ត្រាក់ទ័រ រទេះដាក់ឥវ៉ាន់មានកង់រុញ និងរ៉ឺមក ឬរថសណ្តោងដែលប្រើសំរាប់ដឹកជញ្ជូនគ្រឿងបរិក្ខារ



ឬឥវ៉ាន់ដទៃទៀតដែលនឹងត្រូវយកចូលទៅលើទីវាល មានសក្តានុពលក្នុងការឆ្លងរាលដាលសត្វចង្រៃ។ ការឆ្លងនេះអាចកើតមានពីកង់ ឬពីផ្នែកឯទៀតនៃយានយន្ត ដោយការផ្ទេរគ្រឿងសម្ភារៈឆ្លងរោគដោយផ្ទាល់ ទៅក្នុងកន្លែងផលិតភោគផល។

ចាំបាច់ត្រូវតែមានផែនការសំរាប់គ្រប់គ្រងយានយន្ត។ លទ្ធភាពអាចប្រើប្រាស់យានយន្តត្រូវឲ្យមានភាពងាយស្រួល ក៏ប៉ុន្តែវាចាំបាច់ត្រូវកាត់បន្ថយហានិភ័យ ដែលសត្វចង្រៃនឹងនាំទៅក្នុងចំការរបស់លោកអ្នកផងដែរ។ ចូរវាយតម្លៃហានិភ័យដែលយានយន្តចេញពីចំការ បានដឹកជញ្ជូនសត្វចង្រៃ។ ចូរសួរជាសំនួរ និងក្រឡេកមើលភាពស្អាតបាតតាមសភាពការណ៍របស់យានយន្ត។ លោកអ្នកអាចសម្រេចចិត្តថាហានិភ័យមានកំរិតទាប ហើយអនុញ្ញាតឲ្យគេចូលទៅក្នុងតំបន់ "ស្អាត" របស់លោកអ្នក ឬឲ្យចូលតែក្នុងតំបន់ "ខាងក្រៅ" ប៉ុណ្ណោះ ឬតម្រូវឲ្យលាងចេញមុននឹងចូលក្នុងតំបន់ "ស្អាត"។

វិធីសាស្រ្តដែលមានប្រសិទ្ធិភាពបំផុត គឺការរៀបចំចំការដើម្បីកុំឲ្យយានយន្តដែលចេញចូលលើដីកម្មសិទ្ធិ បានត្រូវគេបើកបរទៅក្នុងតំបន់ "ស្អាត" របស់ចំការ។

ចូរគ្រប់គ្រងចលនារបស់ភ្ញៀវ និងបុគ្គលិកដែលចូលទៅក្នុងតំបន់ "ស្អាត" របស់លោកអ្នកដោយប្រុងប្រយ័ត្ន និងកំណត់ថាតើគេចាំបាច់ត្រូវបើកបរចូលទៅក្នុងតំបន់ "ស្អាត" របស់លោកអ្នកដែរឬទេ។ ការនេះអាស្រ័យលើតួនាទីដែលគេមាននៅលើចំការ និងទំហំចំការរបស់លោកអ្នក។ នៅពេលងាយស្រួលអនុវត្ត ចូរផ្តល់កន្លែងចតយានយន្តដែលនៅឆ្ងាយពីកន្លែងផលិតភោគផលនៃចំការរបស់លោកអ្នក ដូចជានៅជិតផ្ទះដែលលោកអ្នកចតយានយន្តរបស់លោកអ្នកជាដើម។ គឺជាការអាចធ្វើទៅបាន ដែលដឹកជញ្ជូនអ្នកបេះទាំងអស់ ឧទាហរណ៍ ទៅលើទីវាលតាមយានយន្តរបស់ចំការ ជាជាងទុកឲ្យអ្នកបេះម្នាក់ៗបើកបរយានយន្តរបស់គេទៅក្នុងតំបន់ "ស្អាត"។ ចូរប្រើសញ្ញាដើម្បីណែនាំភ្ញៀវ ហើយប្រសិនបើអាចធ្វើបាន ចូរប្រើទ្វារបិទដើម្បីការពារកុំឲ្យអ្នកណាម្នាក់បើកបរចូលក្នុងតំបន់ "ស្អាត" ដោយចៃដន្យ។

ការប្រគល់ឥវ៉ាន់សំរាប់ប្រើក្នុងចំការ និងការផ្ទុកផលដំណាំ ចាំបាច់ត្រូវរៀបចំគម្រោងការដោយប្រុងប្រយ័ត្ន។ លោកអ្នកចាំបាច់ត្រូវតែអាចបញ្ឈប់យានយន្តដែលគេប្រើសំរាប់ប្រគល់/ប្រមូលទំនិញ (រាប់បញ្ចូលទាំងយានយន្តរបស់លោកអ្នកខ្លួនឯងផងដែរ) កុំឲ្យចូលក្នុងតំបន់ "ស្អាត"។ វិធីល្អបំផុតដើម្បីធ្វើឲ្យបានសម្រេចការនេះ គឺត្រូវរៀបចំឲ្យមានជាល្វែងមួយសំរាប់បញ្ឈប់យានយន្តទាំងអស់នៅជាយតំបន់ "ស្អាត"។ សម្ភារៈ និងផលិតផលអាចត្រូវបានផ្ទេរ/ផ្ទុក ដោយពុំចាំបាច់មានយានយន្តសំរាប់ប្រគល់/ប្រមូលទំនិញធ្វើដំណើរទៅក្នុងតំបន់ "ស្អាត" ឡើយ។ មានវិធីខុសៗគ្នាសំរាប់ធ្វើកិច្ចការនេះ។

ឃ្លាំងទុកដាក់ទំនិញដែលមានផ្លូវចូលពីរ និង/ឬរោងសំរាប់វេចខ្ចប់ គឺជាវិធីមួយដ៏ល្អ។ ផ្លូវចូលមួយនៅទល់មុខល្វែង សំរាប់បញ្ឈប់យានយន្តធ្វើដំណើរចេញពីកន្លែងដើម្បីឲ្យទំនិញ អាចផ្ទេរទៅក្នុងរោង ហើយផលិតផលអាចផ្ទុកចេញពីរោង។ ផ្លូវចូលទីពីរនៅទល់មុខកន្លែងផលិតភោគផល ដើម្បីឲ្យគេអាចជញ្ជូនសម្ភារៈទៅមកពីទីវាល និងរោងបាន។ រោងនៅក្នុងស្ថានភាពនេះគឺជាព្រំដែនសំរាប់ដាក់ឲ្យតំបន់ "ស្អាត" និងតំបន់ "ខាងក្រៅ" នៅដាច់ពីគ្នា។

ប្រសិនបើពុំងាយស្រួលដើម្បីមានរោងមានផ្លូវចូលពីរទេ ចំណាត់ការដូចគ្នានេះ អាចត្រូវបានប្រើជាមួយការផ្ទុកនៅកណ្តាលវាល ដោយការបោះគោលចំណាំព្រំដែនរវាងតំបន់ "ស្អាត" និងតំបន់ "ខាងក្រៅ"។ លទ្ធភាពប្រើប្រាស់ប្រេងឥន្ទនៈដែលគេអាចប្រគល់ឲ្យ ត្រូវតែគិតពិចារណាដោយប្រុងប្រយ័ត្ន។ ធុងសំរាប់ស្តុកទុកប្រេងឥន្ទនៈ ចាំបាច់ត្រូវដាក់នៅលើព្រំដែនរវាងតំបន់ "ស្អាត" និងតំបន់ "ខាងក្រៅ" ឬនៅក្នុងតំបន់ "ខាងក្រៅ" ទាំងស្រុង ដើម្បីឲ្យការប្រគល់អាចធ្វើទៅបានដោយពុំមានយានយន្តទាំងនេះចូលទៅក្នុងកន្លែងផលិតភោគផលឡើយ។

ប្រសិនបើពុំងាយស្រួល ដើម្បីបញ្ឈប់យានយន្តដែលធ្វើដំណើរចេញពីចំការកុំឲ្យចូលទៅក្នុងតំបន់ "ស្អាត" ទេ នេះគឺជាការសំខាន់ដែលត្រូវរៀបចំឲ្យមានជាល្វែងមួយសំរាប់លាងចេញនៅលើព្រំដែនរវាងតំបន់ទាំងពីរ។ ប្រសិនបើយានយន្តមួយបាននៅក្នុងកន្លែងដែលមានឆ្លងជម្ងឺ គួរត្រូវលាងសំអាតវាឲ្យបានហ្មត់ចត់។ ចូរយកសំរាម និងសម្ភារៈទាំងអស់ចេញពីយានយន្ត។ ទុយយោបាញ់ទឹកដែលមានសម្ពាធខ្ពស់ ឬប្រដាប់លាងសំអាតដោយប្រើចំហាយទឹកចាំបាច់ត្រូវយកមកប្រើ ដើម្បីយកដី និងចំទេចសំណល់ដំណាំចេញពីកៅស៊ូកង់ តួកង់ និងទម្រជើងយានយន្ត។ រថយន្តមានស្តូក ឬថាសជ្រៅ និងរថយន្តមានតួរាបស្មើគួរ ត្រូវបោសសំអាត និងបាញ់ទឹកលាងវាចេញជាមួយទឹកស្អាត។

ប្រសិនបើលោកអ្នកប្រើអ្នកធ្វើការក្រោមកិច្ចសន្យា ឲ្យធ្វើការសាបព្រោះ បាញ់សាចទឹក និង/ឬច្រូតកាត់ប្រមូលផល ចូរសួរគេអំពីយុទ្ធសាស្រ្តគ្រប់គ្រងហានិភ័យរបស់គេ ដើម្បីការពារកុំឲ្យមានចលនារបស់សត្វចង្រៃទៅមករវាងចំការ។ ចូរសួរអ្នកផ្តល់ការពិគ្រោះយោបល់ផ្នែកដំណាំ អំពីយុទ្ធសាស្រ្តគ្រប់គ្រងហានិភ័យរបស់គេថាតើគេមានប្រដាប់ត្រាំជើង លាងសំអាតដៃ និងឧបករណ៍ ឬផ្លាស់ប្តូរសម្លៀកបំពាក់នៅរវាងចំការដែរឬទេ?

> *"ត្រូវឲ្យមានសកម្មភាពរបស់មនុស្ស ឬត្រាក់ទ័រតិចបំផុត នៅពេលស្លឹកដំណាំសើម ជាពិសេសនៅពេលដែលដំណាំបង្ហាញឲ្យឃើញមានសញ្ញាជម្ងឺដុះផ្សិត ឬបាក់តេរីនៃជម្ងឺលើស្លឹក"*

ពេលវេលាដែលសំខាន់ជាពិសេស ដើម្បីត្រួតពិនិត្យយានយន្ត គ្រឿងម៉ាស៊ីន និងចលនាទៅមករបស់មនុស្ស គឺនៅពេលស្លឹកឈើសើមបន្ទាប់ពីការបាញ់ស្រោចទឹក ឬធ្លាក់ភ្លៀង។ ការនេះត្រូវធ្វើដូច្នេះ ជាពិសេសនៅពេលដំណាំបង្ហាញឲ្យឃើញមានសញ្ញាជម្ងឺដុះផ្សិត ឬបាក់តេរីនៃជម្ងឺលើស្លឹក។

## តំបន់បន្ថយគ្រោះថ្នាក់

តំបន់បន្ថយគ្រោះថ្នាក់ គឺជាយុទ្ធសាស្រ្តគ្រប់គ្រងដ៏សំខាន់ និងមានថ្លៃចំណាយទាប ដែលកាត់បន្ថយហានិភ័យដោយសត្វចង្រៃយាយីដំណាំរបស់លោកអ្នក។ តំបន់បន្ថយគ្រោះថ្នាក់ គឺជាកន្លែងទំនេរដែលត្រូវថែរក្សាឲ្យបានស្អាត ឬត្រូវបានយកវត្ថុឯទៀតដែលអាចជាទីជំរកនៃសត្វល្អិត សត្វចៃ សត្វព្រូន និងជម្ងឺចេញឲ្យអស់។ ដោយល្អឧត្តមបំផុត តំបន់បន្ថយគ្រោះថ្នាក់ទំហំ៥-១០ម៉ែត្រ គួរបានបង្កើតនៅជុំវិញគ្រប់ទីវាលលើចំការ។ ត្រូវថែរក្សាតំបន់បន្ថយគ្រោះថ្នាក់ដែលនៅជុំវិញទីវាលកុំឲ្យមានរុក្ខជាតិ សំរាម ស្រទាប់ដី ឬថ្មចាស់ៗដែលមានអតិសុខុមប្រាណ និងកាកសំណល់ដំណាំទាំងអស់។ កន្លែងនេះអាចត្រូវបិទកុំឲ្យចេញចូល ត្រូវបានក្រាលដោយគ្រួសល្អិត ឬវត្ថុធាតុដែលការពារកុំឲ្យដីស្ងួត អាស្រ័យទៅតាមទំហំកិច្ចប្រតិបត្តិការរបស់លោកអ្នក។

> *" តំបន់បន្ថយគ្រោះថ្នាក់ទំហំ៥-១០ម៉ែត្រ ត្រូវបានណែនាំបង្កើតឲ្យមាននៅជុំវិញកន្លែងផលិតភោគផលលើចំការ "*

ផ្លូវថ្នល់ និងផ្លូវលំអាចប្រើធ្វើផ្នែកនៃតំបន់បន្ថយគ្រោះថ្នាក់នៅជុំវិញទីវាល។

---

ការទទួលស្គាល់: ពត៏មាននៅក្នុងការបោះពុម្ពផ្សាយនេះ បានរៀបចំចេញពី រក្សាវាឲ្យបានស្អាត – កាត់បន្ថយការចំណាយ និងការខាតបង់ក្នុងការគ្រប់គ្រងសត្វចង្រៃ និងជម្ងឺនៅក្នុងរោងដាំបន្លែ និងកូនរុក្ខជាតិ។ Badgery-Parker, J and T Burfield 2009 ជាមួយនឹងគំនិត និងឱវាទបានមកពី Sandra McDougall និង Alison Anderson។

© រដ្ឋញូវសៅវែល តាមរយៈក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ ឆ្នាំ២០១០។ លោកអ្នកអាចចម្លង ចែកចាយ និងដោះស្រាយជាមួយនឹងការបោះពុម្ពផ្សាយតាមរបៀបផ្សេងពីនេះដោយសេរី ដើម្បីគោលបំណងណាមួយ គឺឲ្យតែលោកអ្នកបានបញ្ជាក់ថាក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ គឺជាម្ចាស់កម្មសិទ្ធិនៃការបោះពុម្ពផ្សាយនេះ។

ISSN 1832-6668

ការប្រកាសមិនទទួលខុសត្រូវ: ពត៏មាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺសំអាងលើចំណេះដឹង និងការយល់ដឹងនៅក្នុងពេលកំពុងសរសេរ (ខែមីនា ឆ្នាំ២០១២)។ ទោះជាយ៉ាងនេះក្តី ដោយសារការជឿនលឿនផ្នែកចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកអំពីសេចក្តីត្រូវការដើម្បីឲ្យប្រាកដច្បាស់ថា ពត៏មានដែលគេពឹងផ្អែកទៅលើ មានលក្ខណៈទាន់ពេល និងសំរាប់ឆែកមើលបច្ចុប្បន្នភាពនៃពត៏មានជាមួយភ្នាក់ងារសមស្របរបស់ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ឬអ្នកផ្តល់ឱវាទឯករាជ្យសំរាប់អ្នកប្រើប្រាស់។

ចុះផ្សាយដោយក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ដែលជាផ្នែកមួយរបស់ក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ។

Trim referenceINT 12/24530

Horticulture Australia

ការផលិតប័ណ្ណពត៏មាននេះ និងការបកប្រែភាសាបានទទួលការផ្គត់ផ្គង់ប្រាក់មួយ ចំណែកពីគំរោងដែលទទួលប្រាក់ឧបត្ថម្ភរបស់ HAL អង្គការដំណាំវប្បកម្មអូស្រ្តាលី): *ការដោះស្រាយអំពីគុណភាព និងសុវត្ថិភាពនៃផលិតផលជាមួយអ្នកដាំដុះនៃឧស្សាហកម្មបន្លែដែលនិយាយភាសាក្រៅពីភាសាអង់គ្លេស* ការផ្តើមគំនិតនៃកម្មវិធីអភិវឌ្ឍន៍ឧស្សាហកម្ម បន្លែ។